**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០១៥

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 07-Aug-2015, 15:28
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ ដោយឧបសម្ព័ន្ធមួយជាឯកសារសម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលសវនាការលើការថ្លែងពីការឈឺចាប់ ទាក់ទិននឹងវគ្គជំនុំជម្រះទីពីរ របស់សហមេធាវីនាំមុខ**
**(ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់)**

---

**<u>ដាក់ដោយ</u>៖**

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>៖**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

**<u>នៅចំពោះមុខ</u>៖**

**<u>អង្គជំនុំជម្រះសាលាដំបូង</u>៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

Original EN: 01120926-01120930

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉េន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini YE

## I. សេចក្តីផ្តើម

1. អនុលោមតាមឯកសារ E315/1 និងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥[1] ទាក់ទិននឹងសវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីការស្នើឡើងនូវកាលបរិច្ឆេទ និងការជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខ ដើម្បីជួយជំរុញផែនការបញ្ចប់វគ្គសវនាការនាពេលបច្ចុប្បន្ននេះ។

## II. សាវតារនីតិវិធី

2. ផ្អែកទៅលើការអនុវត្តដែលមាននាពេលកន្លងមក អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីទាំងអស់ថា បន្ទាប់ពីការធ្វើសវនាការបង្ហាញឯកសារគន្លឹះនៅចុងបញ្ចប់នៃវគ្គសវនាការនីមួយៗ អង្គជំនុំជម្រះនឹងរក្សាពេលពីរថ្ងៃដើម្បីស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីអំពីផលប៉ះពាល់ ដែលពួកគាត់បានទទួលរងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[2]។

3. អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យសហមេធាវីនាំមុខផ្តល់បញ្ជីអាទិភាពនៃដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវមកផ្តល់សក្ខីកម្មអំពីផលប៉ះពាល់ និងព្យសនកម្មដែលពួកគាត់បានទទួលរងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ជាពិសេសពាក់ព័ន្ធនឹងវគ្គជំនុំជម្រះទីពីរ ទាក់ទិននឹងការដ្ឋានការងារ នៅត្រឹមថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥[3]។

---

[1] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនទៅភាគីទាំងអស់ស្តីពីសវនាការលើឯកសារគន្លឹះ និងសវនាការលើការថ្លែងពីការឈឺចាប់ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥។ *សូមមើល ផងដែរ* សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ ស្តីពី សាក្សីបន្ទាប់ការជូនដំណឹងទៅភាគី ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥។

[2] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា ព័ត៌មានអំពី (១) សវនាការអំពីការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ឯកសារ **E315/1** ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៧-៩។

[3] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនទៅភាគីទាំងអស់ ស្តីពីសវនាការអំពីឯកសារគន្លឹះ និងសវនាការលើការថ្លែងពីការឈឺចាប់ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥។ សូមមើល ផងដែរ សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ ស្តីពី សាក្សីបន្ទាប់ការជូនដំណឹងទៅភាគី ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥។

## III. ការពិភាក្សា

4. សហមេធាវីនាំមុខ ដោយសហការជាមួយនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានពិនិត្យមើលយ៉ាងល្អិតល្អន់ទៅលើដើមបណ្តឹងរដ្ឋប្បវេណី ដែលមានការជាប់ពាក់ព័ន្ធច្រើនទៅនឹងវគ្គជំនុំជម្រះទីពីរ ហើយបានបង្កើតបញ្ជីឈ្មោះចុងក្រោយដែលមានបុគ្គលចំនួនប្រាំនាក់ ដែលមានបំណងផ្តល់សក្ខីកម្មនៅក្នុងអំឡុងសវនាការនាពេលខាងមុខនេះអំពីព្យសនកម្មដែលពួកគាត់បានទទួលរង។

5. ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្នើឡើងទាំងអស់នេះបានទទួលរង ព្យសនកម្មជាជនរងគ្រោះដោយផ្ទាល់ ឬដោយប្រយោលនៃឧក្រិដ្ឋកម្មទាំងឡាយដែលពួកគាត់នឹង ធ្វើការរៀបរាប់។ លើសពីនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្នើឡើងទាំងអស់នេះ ត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលស្គាល់ ដោយសារតែបានទទួលរងព្យសនកម្មនៅឯការដ្ឋានមួយក្នុងចំណោមការដ្ឋានការងារចំនួនបីកន្លែង ដែលត្រូវបានដាក់បញ្ចូលនៅក្នុងវគ្គជំនុំជម្រះទីពីរនេះ។

6. សហមេធាវីនាំមុខស្នើឡើងនូវកាលបរិច្ឆេទមួយសម្រាប់សវនាការចំនួនពីរថ្ងៃនេះ ដោយសេចក្តីលម្អិតនៃកាលបរិច្ឆេទនេះមាននៅក្នុងឧបសម្ព័ន្ធ I ដែលភ្ជាប់មកជាមួយនឹងសំណើនេះ (“កាលបរិច្ឆេទបណ្តោះអាសន្ន និងដែលបានស្នើឡើង”)[4]។ កាលបរិច្ឆេទដែលបានស្នើឡើង ផ្អែកទៅលើការប៉ាន់ស្មានថា សវនាការក្នុងមួយថ្ងៃមានរយៈពេលប្រមាណបួនម៉ោងដប់នាទី[5]។

7. សហមេធាវីនាំមុខបន្ថែមថា សវនាការទាំងនេះមានគោលបំណងផ្តល់វេទិកាជូនដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបង្ហាញពីការឈឺចាប់របស់ពួកគាត់ក្នុងនាមជាជនរងគ្រោះ និងផលប៉ះពាល់នៃព្យសនកម្មដែលពួកគាត់បានទទួលរងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ជាការពិត ព្យសនកម្ម និងការឈឺចាប់ដែលបានទទួលរងនៅក្នុងអំឡុងរយៈពេលនេះ ពាក់ព័ន្ធទៅនឹងអង្គហេតុនានានៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ហើយចាំបាច់ត្រូវពិពណ៌នានៅក្នុងអំឡុងពេលសវនាការទាំងនេះ។

---

[4] ឧបសម្ព័ន្ធ I កាលបរិច្ឆេទដែលបានស្នើឡើងសម្រាប់សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណី។

[5] រយៈពេលបួនម៉ោងដែលត្រូវបានស្នើឡើងសម្រាប់ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី មិនរាប់បញ្ចូលរយៈពេលឈប់សម្រាកពីរដងជាធម្មតានោះឡើយ។

8. សហមេធាវីនាំមុខយល់ថា ប្រសិនបើអង្គហេតុទាំងនេះត្រូវបានភាគីដទៃទៀតជំទាស់តវ៉ា នោះនឹងត្រូវមានការផ្តល់ពេលវេលាសមស្របដើម្បីធ្វើការសួរដេញដោល ដោយត្រូវគិតពីផលប្រយោជន៍របស់អង្គជំនុំជម្រះនៅក្នុងការស្វែងរកការពិត សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ និងតុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់។ នៅទន្ទឹមពេលជាមួយគ្នានេះដែរ ដើម្បីឲ្យសវនាការនេះនៅតែមានភាពជាប់ពាក់ព័ន្ធនោះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែមានលទ្ធភាពបញ្ចប់សក្ខីកម្មអំពីព្យសនកម្មរបស់ពួកគាត់ឲ្យបានពេញលេញនៅក្នុងរយៈពេលដែលបានផ្តល់ទៅឲ្យពួកគាត់នោះ ហើយមិនត្រូវបានប៉ះពាល់ដោយការជំទាស់នានារបស់ភាគីដែលអាចកើតមាននោះឡើយ។

9. លើសពីនេះទៀត ដើម្បីបន្ធូរក្តីកង្វល់ជុំវិញសវនាការលើផលប៉ះពាល់នៃវគ្គជំនុំជម្រះទៅលើសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងដោយកត់សម្គាល់អំពីអង្គហេតុដែលថា អង្គជំនុំជម្រះសាលាដំបូងនឹងមិនផ្តល់ពេលវេលាបន្ថែមទៀតដើម្បីឲ្យភាគីដទៃទៀតតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីនោះ[6] សហមេធាវីនាំមុខបានបញ្ចូលពេលវេលាបន្ថែមទៀតសម្រាប់ភាគី ទៅក្នុងកាលវិភាគដែលបានស្នើឡើង ដែលមានការប៉ាន់ស្មានពីពេលវេលាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗផង។

10. លើសពីនេះទៀត សហមេធាវីនាំមុខរំពឹងថា ពេលវេលាបន្ថែមនេះនឹងជួយសម្រួលដល់គោលបំណងចម្បងនៃសវនាការទាំងនេះ និងសិទ្ធិរបស់ភាគីទាំងអស់។ ការមានពេលវេលាបន្ថែមនេះក៏នឹងអនុញ្ញាតឲ្យអង្គជំនុំជម្រះពិចារណាផ្តល់ឱកាសឲ្យភាគីក្នុងការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ប្រសិនបើមានលេចចេញនូវអង្គហេតុថ្មី ឬការចោទប្រកាន់ថ្មីប្រឆាំងនឹងជនជាប់ចោទនោះ[7]។

---

[6] សារអេឡិចត្រូវនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនទៅភាគីទាំងអស់ ស្តីពីសវនាការអំពីឯកសារគន្លឹះ និងសវនាការលើការថ្លែងពីការឈឺចាប់ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥។

[7] *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា ព័ត៌មានអំពី (១) សវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ឯកសារ **E315/1** ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៨៖ "នៅក្នុងករណីដែលសេចក្តីថ្លែងពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហើបនូវអង្គហេតុថ្មី ឬការចោទប្រកាន់ថ្មីប្រឆាំងនឹងជនជាប់ចោទដែលមិនទាន់បានពិភាក្សា

## IV. សំណើ

11. ដោយយោងទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងអនុម័តទៅលើកាលបរិច្ឆេទដែលបានស្នើឡើង និងសូម៖

ក) កោះហៅដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះនៅក្នុងបញ្ជី និងអនុលោមតាមកាលបរិច្ឆេទបណ្តោះអាសន្ន និងដែលបានស្នើឡើង និង

ខ) បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ចាប់ផ្តើមរៀបចំសម្រាប់ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើង ដោយអនុលោមតាមកាលបរិច្ឆេទដែលបានស្នើឡើង។

សូមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយសេចក្តីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៧ខែ សីហា ឆ្នាំ ២០១៥ | ពេជ អង្គ<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ | |

ដេញដោលនោះ អង្គជំនុំជម្រះអាចពិចារណាដើម្បីផលប្រយោជន៍យុត្តិធម៌ក្នុងការផ្តល់ឱកាសឱ្យភាគី តាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ ពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងនោះបាន”។